00887086

E246/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 13 / 02 / 2013
ម៉ោង (Time/Heure): 15 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: ..........

សាធារណៈ / Public

អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០១៣

**ជូនចំពោះ÷** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី:** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង, ប្រធានអង្គភាពបកប្រែភាសា**

**កម្មវត្ថុ:** **ចម្លើយតបទៅនឹងសំណើ E246 និង E185/1/1 និងសំណើផ្សេងៗមួយចំនួនពាក់ព័ន្ធនឹងឯកសារ និងពេលវេលាកំណត់**

១. មេធាវីការពារក្តី ខៀវ សំផន ស្នើសុំឱ្យមានសវនាការផ្ទាល់មាត់មួយដើម្បីពិភាក្សាដេញដោលថាតើកំណត់ហេតុនៃការស្តាប់ចម្លើយ ចម្លើយរបស់សាក្សី បណ្តឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់បុគ្គលទាំងឡាយ ដែលពុំត្រូវបានកោះហៅឱ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ គួរត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដែរឬយ៉ាងណា (ឯកសារ E246)។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យមានការទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយ ដែលបានដាក់ជំនួសឱ្យការផ្តល់ភស្តុតាងដោយផ្ទាល់មាត់ (ឯកសារ E96) ដែលបន្ទាប់ពីពេលនោះមក ភាគីបានមានឱកាសដើម្បីធ្វើសេចក្តីសន្និដ្ឋាននានាស្តីពីការគ្រប់គ្រងគោលការណ៍គតិយុត្ត និងការស្នើសុំដាក់នូវកំណត់ហេតុស្តាប់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះ (*សូមមើល ឧទាហរណ៍* ឯកសារ E96/1, E96/2, E96/3, E96/4, E131/6, E114, E114/1)។ អង្គជំនុំជម្រះបានចេញសេចក្តីសម្រេចរបស់ខ្លួន ដែលបានកំណត់អំពីគោលការណ៍គតិយុត្តទាំងឡាយដែលអាចអនុវត្តបានចំពោះកំណត់ហេតុស្តាប់ចម្លើយទាំងនោះ (ឯកសារ E96/7) និងបានបញ្ជាក់ថាគោលការណ៍ទាំងនេះអនុវត្តបានចំពោះតែកំណត់ហេតុស្តាប់ចម្លើយ ដែលសហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយក ព្រមទាំងបណ្តឹង និងពាក្យសុំ

តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីប៉ុណ្ណោះ (ឯកសារ E223/2)។ លើសពីនេះទៀត អង្គជំនុំជម្រះក៏បានផ្ដល់ឱកាសបន្ថែមទៅឱ្យភាគីដើម្បីដាក់នូវសេចក្ដីជំទាស់របស់ខ្លួន ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយទាំងនេះរហូតដល់ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៣។ ហេតុដូច្នេះ អង្គជំនុំជម្រះពិចារណាឃើញថា អង្គជំនុំជម្រះបានផ្ដល់ឱកាសពេញលេញទៅភាគី ដើម្បីរៀបចំសេចក្ដីជំទាស់ទាំងឡាយទៅនឹងកំណត់ហេតុស្ដាប់ចម្លើយណាមួយ ឬធ្វើសេចក្ដីសង្កេតទៅលើឯកសារទាំងនោះ។ ហេតុនេះ អង្គជំនុំជម្រះតម្រូវឱ្យភាគីដាក់នូវសេចក្ដីជំទាស់របស់ខ្លួន និងសេចក្ដីសង្កេតបន្ថែមណាមួយប្រសិនបើមាន ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយទាំងនេះនៅក្នុងសារណារួមមួយឱ្យបានត្រឹម ឬ មុនកាលបរិច្ឆេទខាងលើ។ អង្គជំនុំជម្រះសាលាដំបូងក៏ទទួលយកសំណើរបស់សហព្រះរាជអាជ្ញាដែលបានផ្ញើរតាមរយៈសារអេឡិចត្រូនិកមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី ១៦ និងថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១២ ដែលបានស្នើសុំការឆ្លើយតបទៅនឹងសេចក្ដីជំទាស់នានាដែលក្រុមមេធាវីការពារក្ដីបានដាក់នៅក្នុងសារណារួមមួយ។ អង្គជំនុំជម្រះតម្រូវឱ្យសហព្រះរាជអាជ្ញាដាក់ចម្លើយតបរួមនេះនៅក្នុងរយៈពេល ១ ខែ ក្រោយថ្ងៃដែលក្រុមមេធាវីការពារក្ដីទាំងអស់បានដាក់នូវសេចក្ដីជំទាស់របស់ពួកគេ ឬឱ្យបានត្រឹមថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១៣ ឬ ឆាប់ជាងនេះ។

២. បន្ថែមពីលើនេះ មេធាវីការពារក្ដី ខៀវ សំផន បានស្នើសុំការបញ្ជាក់បំភ្លឺអំពីប្រភេទឯកសារដែលបានដាក់ក្រោមលេខ E3 (ឯកសារ E246)។ មេធាវីការពារក្ដី ខៀវ សំផន បានកត់សម្គាល់អំពីការទទួលស្គាល់របស់អង្គជំនុំជម្រះសាលាដំបូងដែលថា "ភាគីពុំអាចលើកភស្តុតាងណាមួយប្រឆាំងនឹងជនជាប់ចោទ ប្រសិនបើភស្តុតាងនោះមិនទាន់បានឆ្លងកាត់ការលើកទឡ្ហីករណ៍តទល់" (ឯកសារ E223/2, កថាខណ្ឌ ១២) និងបានលើកឡើងថា ការដាក់លេខសម្គាល់ E3 របស់អង្គជំនុំជម្រះសាលាដំបូងចំពោះកំណត់ហេតុស្ដាប់ចម្លើយសាក្សី នៅមុនឱកាសនៃការដាក់សេចក្ដីជំទាស់ទៅនឹងឯកសារទាំងនោះ គឺជាការឆាប់រហ័សពេក (ឯកសារ E246 កថាខណ្ឌ ៨)។ ក្របខណ្ឌគតិយុត្តជាធរមាននៃការដាក់កំណត់ហេតុស្ដាប់ចម្លើយនៅចំពោះមុខអង្គជំនុំជម្រះ និងការដាក់លេខសម្គាល់ E3 ត្រូវបានលើកឡើងនៅក្នុងសេចក្ដីសម្រេច E96/7។ សេចក្ដីសម្រេចនេះក៏បានបញ្ជាក់បំភ្លឺថាលក្ខខណ្ឌនានាដែលមាននៅក្នុងផ្នែក ៤.២ និង ៤.៣ នៃសេចក្ដីសម្រេចនោះ ដែលនឹងត្រូវបានអង្គជំនុំជម្រះពិនិត្យពិចារណា នៅពេលវាយតម្លៃអំពីតម្លៃជាភស្តុតាង និងការផ្ដល់ទម្ងន់ចំពោះភស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្រោយការចេញសេចក្ដីសម្រេចនេះ។ សេចក្ដីសម្រេច E96/7 ក៏បានកត់សម្គាល់ផងដែរថាភាគីនឹងត្រូវបានផ្ដល់ឱកាស

ដើម្បីដាក់សេចក្ដីជំទាស់ពាក់ព័ន្ធនានា ទៅនឹងកំណត់ហេតុស្ដាប់ចម្លើយ ដែលភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅក្នុងអំឡុងសវនាការនាពេលខាងមុខ ឬយ៉ាងណានោះទេ (ឯកសារ E96/7 កថាខណ្ឌ ៣៦)[1]។ យោងតាមកាលបរិច្ឆេទដែលបានកំណត់ខាងលើសម្រាប់ការដាក់សេចក្ដីជំទាស់ជាលាយលក្ខណ៍អក្សរ ទៅនឹងកំណត់ហេតុនៃការស្ដាប់ចម្លើយ ចម្លើយរបស់សាក្សីបណ្ដឹង និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់បុគ្គលទាំងឡាយ ដែលពុំត្រូវបានកោះហៅឲ្យមកផ្ដល់សក្ខីកម្ម ហើយដែលភាគីអាចជំទាស់នោះ អង្គជំនុំជម្រះបដិសេធបណ្ដឹងរបស់មេធាវីការពារក្ដី ខៀវ សំផន ដែលថាក្រុមខ្លួនត្រូវបានបដិសេធនូវឱកាសសម្រាប់ធ្វើការតទល់លើភស្តុតាងទាំងនេះ។ នៅដំណាក់កាលនេះ អង្គជំនុំជម្រះពុំពិចារណាឃើញថាការធ្វើសវនាការដោយផ្ទាល់មាត់លើបញ្ហាទាំងនេះ មានភាពសមស្របឡើយ។

៣. ដោយហេតុថាកំណត់ហេតុស្ដាប់ចម្លើយសាក្សីខ្លះ ពុំមានជា ៣ ភាសាផ្លូវការនៅ អ.វ.ត.ក នោះទេ ហេតុដូច្នេះកាលពីពេលកន្លងទៅនេះ អង្គជំនុំជម្រះបានអនុញ្ញាតឲ្យភាគីប្រើប្រាស់ឯកសារសម្ភារៈដែលមានតែ ១ ឬ ២ ភាសាផ្លូវការនៅ អ.វ.ត.ក ប៉ុណ្ណោះ។ អង្គជំនុំជម្រះបានកំណត់នូវកាលបរិច្ឆេទចុងក្រោយត្រឹមថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ ទៅសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីទទួលបានការបកប្រែជា ៣ ភាសាផ្លូវការនូវកំណត់ហេតុស្ដាប់ចម្លើយ និងពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនានាដែលពួកគាត់មានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E223/2; *សូមមើលផងដែរ* ឯកសារ E185/1)។ សហព្រះរាជអាជ្ញាស្នើសុំការបញ្ជាក់បំភ្លឺថាតើកាលបរិច្ឆេទចុងក្រោយនេះ កំហិតត្រឹមកំណត់ហេតុស្ដាប់ចម្លើយ ឬក៏ថាកាលបរិច្ឆេទចុងក្រោយនេះអនុវត្តចំពោះរាល់ឯកសារទាំងអស់ ដែលត្រូវបានស្នើសុំដាក់

---

[1] *សូមមើល ផងដែរ* ឯកសារ E96/7, កថាខណ្ឌ ៣៥(ឃ) និងផ្នែកសម្រេចសេចក្ដី និងអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា៖ "សវនាការផ្ទាល់មាត់បន្ថែមលើឯកសារ ( ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១២), ឯកសារ E172/1, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ ជើងទំព័រ ១ "(ឯកសារប្រភេទ A12 និង A13 [ចម្លើយជាលាយលក្ខណ៍អក្សរ] នឹងត្រូវសម្រេចតាមរយៈសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរដែលកំពុងស្ថិតក្រោមការពិចារណារបស់អង្គជំនុំជម្រះ។ ហេតុដូច្នេះ ឯកសារទាំង ០២ ប្រភេទនេះនឹងពុំត្រូវបានកំណត់យកមកដេញដោលនៅក្នុងសវនាការផ្ទាល់មាត់លើឯកសារឡើយ") និងបច្ចុប្បន្នភាពទៅលើអនុស្សរណៈស្ដីពីសវនាការលើឯកសារនៅដំណាក់កាល បន្ទាប់ (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២) ឯកសារ E172/5 ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១២ ជើងទំព័រ ១ ("ឯកសារប្រភេទ A12 និង A13 នឹងត្រូវសម្រេចតាមរយៈសេចក្ដីសម្រេចជាលាយលក្ខណ៍អក្សរមួយដែលកំពុងស្ថិតក្រោមការពិចារណារបស់អង្គជំនុំជម្រះ។ ហេតុដូច្នេះនៅដំណាក់កាលនេះ ឯកសារទាំង ០២ ប្រភេទនេះនឹងពុំត្រូវបានកំណត់យកមកដេញដោលនៅក្នុងសវនាការផ្ទាល់មាត់លើឯកសារឡើយ")។

នៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ E185/1/1)។ អង្គជំនុំជម្រះសូមបញ្ជាក់ថាគោលបំណងនៃការកំណត់កាលបរិច្ឆេទចុងក្រោយនេះ គឺដើម្បីធានាថារាល់ឯកសារសម្ភារៈ*ទាំងអស់* ដែលត្រូវបានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយក មានជា ៣ ភាសាផ្លូវការនៅ អ.វ.ត.ក បានដាក់មកទាន់ពេលវេលា។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឱ្យភាគីពិគ្រោះជាមួយអង្គភាពបកប្រែភាសា ដើម្បីធានាបានថាភស្តុតាងគ្រប់ប្រភេទទាំងអស់ដែលភាគីបានស្នើសុំមានជា ៣ ភាសានៅត្រឹមកាលបរិច្ឆេទថ្ងៃទី ៤ ខែ មីនា ឆ្នាំ ២០១៣ ហើយឯកសារសម្ភារៈទាំងអស់ដែលភាគីនឹងបង្ហាញអាចមានជា៣ភាសាផ្លូវការនៅ អ.វ.ត.ក ចំពោះមុខអង្គជំនុំជម្រះ មុនពេលនៃការបញ្ចប់កិច្ចពិភាក្សាដេញដោលលើភស្តុតាងក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះក៏សូមរំឭកភាគីថាប្រសិនបើភាគីពុំអាចប្រគល់ឯកសារសម្ភារៈដែលត្រូវបានដាក់ជាភស្តុតាងមកអង្គជំនុំជម្រះបានទាន់ពេលវេលាទេនោះ ឯកសារសម្ភារៈទាំងនោះមិនអាចចាត់ទុកថាបានដាក់នូវចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងឡើយ។

៤. ជាចុងក្រោយ អង្គជំនុំជម្រះបានឃើញលិខិតចុះថ្ងៃទី ៦ ខែ កុម្ភៈ ឆ្នាំ ២០១៣ ដែលមេធាវីការពារក្ដី អៀង សារី បានផ្ញើរមកមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដោយបានស្នើសុំនូវឱកាសដើម្បីលើកការជំទាស់បន្ថែមទៅនឹងឯកសារថ្មីៗ ដែលបានស្នើសុំដោយសហព្រះរាជអាជ្ញានៅក្នុងឧបសម្ព័ន្ធ ក២១ និងឯកសារថ្មីៗរបស់ភាគីផ្សេងទៀត។ អង្គជំនុំជម្រះទទួលយកនូវសំណើសុំនេះ និងបង្គាប់ឱ្យមេធាវីការពារក្ដី អៀង សារី ដាក់នូវសេចក្ដីជំទាស់ទាំងនោះ ជាលាយលក្ខណ៍អក្សរឱ្យបានត្រឹមថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣។

៥. នេះគឺជាចម្លើយតបជាផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងរាល់សារណា និងសំណើសុំទាំងអស់ខាងលើ។